ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំខែឧសភា ឆ្នាំ២០២០ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងខែឧសភា ឆ្នាំ២០២០នេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាធ្វើការដាំដុះបានចំនួន ៦៣៩ ១៥៨ហ.ត ស្មើនឹង២៤,៧០% នៃផែនការចំនួន ២ ៥៨៨ ១៣០ហ.ត និងស្ថានភាពទឹកភ្លៀងធ្លាក់នៅក្នុងតំបន់ពីកម្រិតខ្សោយទៅបង្គួរនៅតាមរាជធានី-ខេត្ត។ រីឯការចូលរួមទប់ស្កាត់បទល្មើសផ្សេងៗទៀតជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផលក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង ព្រមទាំងបទល្មើសចលនាសត្វដោយខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងខែឧសភា ឆ្នាំ២០២០ នេះ គឺបានរៀបចំកិច្ចប្រជុំសំខាន់ៗ រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។ ចំពោះលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ២០២០ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុងខែឧសភា ឆ្នាំ២០២០នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ លទ្ធផលផ្នែកដាំដុះ

#### ១.១ ផលិតកម្មដំណាំស្រូវរដូវវស្សា

ល្បឿនការងារបង្កបង្កើនផលដំណាំស្រូវរដូវវស្សាគិតត្រឹមថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០ មានលម្អិតដូចខាងក្រោម៖

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ៨៤៧ ៤៨៤ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ២ ២០២ហ.ត និងដោយគ្រឿងយន្តមានចំនួន ៨៤៥ ២៨២ហ.ត លើសឆ្នាំមុនចំនួន ៤៩១ ៣១២ហ.ត
- ផ្ទៃដីសាបសម្រេចបានចំនួន ៥៤៨ហ.ត លើសឆ្នាំមុនចំនួន ៥៤៥ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ៦៣៩ ១៥៨ហ.ត ស្មើនឹង២៤,៧០% នៃផែនការចំនួន ២ ៥៨៨ ១៣០ហ.ត លើសឆ្នាំមុនចំនួន ១៥៥ ១៥១ហ.ត។

#### ១.២ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរដូវវស្សា

-ដំណាំរួមផ្សំអនុវត្តបានសរុបចំនួន ២៥ ១៥៣ហ.ត ស្មើនឹង៥០,៩០% នៃផែនការចំនួន ៤៩ ៤២០ហ.ត លើសឆ្នាំមុនចំនួន ១១ ០៥១ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៣២៨ ១២៦ហ.ត ស្មើនឹង៣៧,៥២% នៃផែនការចំនួន ៨៧៤ ៥៩៥ហ.ត លើសឆ្នាំមុនចំនួន ៦៩ ៦៨៧ហ.ត។

#### ១.៣ ការនាំចេញអង្ករ

បរិមាណនាំចេញអង្ករបានចំនួន ៥៥ ៨៤៥តោន មានការកើនឡើងចំនួន ១៩ ៤៣៦តោន (+៥៣.៣៨%) ច្រើនជាងបរិមាណនាំចេញក្នុងខែឧសភា ឆ្នាំ២០១៩ ដែលមានចំនួន ៣៦ ៤០៩តោន។ សរុបរយៈពេល៥ខែនាំចេញអង្ករ

បានចំនួន ៣៥៦ ០៩៧តោន និងបាននាំចេញទៅកាន់ទិសដៅចំនួន ៥៤ប្រទេស ក្នុងនោះប្រទេសចិនឈរលំដាប់ទី១ (១៣៦ ៨២៥តោន) ប្រទេសបារាំងឈរលំដាប់ទី២ (៤៥ ២៦៧តោន) ប្រទេសម៉ាឡេស៊ីឈរលំដាប់ទី៣ (១៧ ៦៧៣តោន) ប្រទេសណេដឺឡែនឈរលំដាប់ទី៤ (១៤ ៦៦៦តោន) ប្រទេសវៀតណាមឈរលំដាប់ទី៥ (១២ ៧០០តោន) ប្រទេសអង់គ្លេសឈរលំដាប់ទី៦ (៩ ៧១៤តោន) ប្រទេសប៉ូឡូញឈរលំដាប់ទី៧ (៨ ៩៨៧តោន) ប្រទេសអេស្ប៉ាញឈរលំដាប់ទី៨ (៧ ៨៦៤តោន) ប្រទេសបែលហ្ស៊ិក ឈរលំដាប់ទី៩ (៧ ៣៨៩តោន) និងប្រទេសប្រ៊ុយណេលំដាប់ទី១០ (៧ ៣៥០តោន) ហើយបច្ចុប្បន្នក្រុមហ៊ុនបាននាំចេញអង្ករមានចំនួន ៦៥ក្រុមហ៊ុន។

## ២ ផ្នែកផលិតកម្មកៅស៊ូ (ខែចាស់)

### ២.១ ផ្ទៃដីកៅស៊ូ

- ផ្ទៃដីកៅស៊ូសរុបចំនួន ៤០៤ ៨០១ហ.ត ក្នុងនោះ ផ្ទៃដីចៀរជ័រចំនួន ២៥០ ០៦៦ហ.ត ស្មើនឹង៦២% និងផ្ទៃដីថែទាំចំនួន១៥៤ ៧៣៥ហ.ត ស្មើនឹង៣៨%។

### ២.២ ផលិតកម្មកៅស៊ូ

- ផលិតផលជ័រកៅស៊ូសម្រេចបានចំនួន ១៨ ៩៦១តោន កើនឡើងចំនួន ៨ ១៣៧តោន ស្មើនឹង៧៥% ធៀបខែមុន និងកើនឡើងចំនួន ៤ ៥៤១តោន ស្មើនឹង៣១% ធៀបខែឧសភា ឆ្នាំ២០១៩។

### ២.៣ ការនាំចេញកៅស៊ូ

- បរិមាណបញ្ចេញលក់សម្រេចបានចំនួន ១៨ ៦០៤តោន កើនចំនួន ៦ ៨៥៣តោន ស្មើនឹង៥៨% ធៀបខែមុន និងកើនឡើងចំនួន ៣ ៣២២តោន ស្មើនឹង២២% ធៀបខែឧសភា ឆ្នាំ២០១៩។

### ២.៤ តម្លៃកៅស៊ូ

- តម្លៃលក់មធ្យម គឺ ១ ១៩២ដុល្លារ/តោន ថយចុះចំនួន ២០៥ដុល្លារ/តោន ស្មើនឹង១៤,៦៧% ធៀបខែមុន និងថយចុះចំនួន ១៧៣ដុល្លារ/តោន ស្មើនឹង១៣% បើធៀបខែឧសភា ឆ្នាំ២០១៩
- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារចម្ការ គឺទឹកជ័រ (DRC 100%) និងជ័រកក (DRC50%) គឺពុំមានការលក់ដោយសារសម្រាកចៀរជ័រ។

## ៣ ផ្នែកព្រៃឈើ

### ៣.១ ការងារព្រៃឈើ

- បានទាញយករូបភាពផ្កាយរណប (Landsat8) ឆ្នាំ២០២០ ចំនួន ៥ផ្ទាំង និង (Sentinel2) ឆ្នាំ២០២០ ចំនួន ៥ផ្ទាំងសម្រាប់បន្តវាយតម្លៃគម្របព្រៃឈើឆ្នាំ២០២០
- បានចុះពិនិត្យការរៀបចំដី ការដាំដុះចម្ការកសិ-រុក្ខកម្ម និងដំណាំកសិកម្មចម្រុះចំនួន ៥កន្លែង មានសហគមន៍ព្រៃឈើជ្រោះស្វាយ សហគមន៍ព្រៃឈើដំរីចាក់ធ្លក សហគមន៍ព្រៃឈើអូរពោងពោង សហគមន៍ព្រៃឈើព្រៃក្បាលបី និងសហគមន៍ព្រៃឈើព្រៃហ៊ុំ
- បានផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តចំនួន ៣២គ្រឿង និងយានយន្តចំនួន ២៩គ្រឿង ជូនក្រុមហ៊ុនចំនួន ៣ គឺក្រុមហ៊ុនអេច អឹម អឹម នៅខេត្តតាកែវ ក្រុមហ៊ុនហ្វេនឌីស នៅខេត្តកំពង់ស្ពឺ ក្រុមហ៊ុនអេសខេ នៅខេត្តរតនគិរី
- បានរៀបចំលិខិតបើកផ្លូវដឹកជញ្ជូនអនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន ២ក្រុមហ៊ុន និងអ្នកស្នើសុំចំនួន ១នាក់ មានឈើមូលចំនួន ១ ៤២៧ម៣ ឈើអារចំនួន ៧៩០ម៣ ក្រាក់ចំនួន ៩ម៣ កូនឈើចំនួន ៩ ៣៧១ដើម អុសចំនួន ១១០ស្ទែរ ជ័រទឹកចំនួន ៤០តោន និងធ្យូងចំនួន ៦ ៥១៥គ.ក្រ។

### ៣.២ ការងារអភិរក្សសត្វព្រៃ

- បានចុះសិក្សាស្រាវជ្រាវតាមដានវត្តមានសត្វព្រៃចំនួន ១លើកនៅក្នុងតំបន់សហគមន៍កំពង់ស្រឡៅ ខេត្តព្រះវិហារ ដោយក្រុមការងារបានកត់ត្រានូវប្រភេទថនិកសត្វចំនួន ៣៦ប្រភេទ បក្សីចំនួន ៦៦ប្រភេទ និងឧរង្គសត្វចំនួន ៣៣ប្រភេទ
- បានចុះពិនិត្យសំណើសុំថែរក្សាសត្វក្រចៅកកាំជាលក្ខណៈគ្រួសារចំនួន ១លើក នៅក្នុងខេត្តកោះកុង កណ្តាល និងខេត្តតាកែវ។

### ៣.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- កសិដ្ឋានចំនួន ៧កន្លែង បានថែរក្សា និងបង្កាត់ពូជស្វាក្តាមសរុបចំនួន ៦៤ ០៦៣ក្បាល ក្នុងនោះ កូនកើតក្នុងខែចំនួន ៣ ៣១០ក្បាល ដឹកជញ្ជូនក្នុងស្រុកចំនួន ៥០០ក្បាល និងដឹកជញ្ជូនឆ្ពោះទៅកាន់ច្រកអន្តរជាតិសម្រាប់នាំចេញទៅក្រៅប្រទេសចំនួន ២ ១២០ក្បាល

- នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានសត្វព្រៃសរុបចំនួន ១ ៨៧៩ក្បាល (បក្សីចំនួន ៥៦ប្រភេទ ថនិកសត្វចំនួន ៤៦ប្រភេទ និងល្មូនចំនួន ១៦ប្រភេទ) សង្គ្រោះសត្វថ្មីចំនួន ៥៤ក្បាល ព្យាបាលសត្វព្រៃរបួសឈឺចំនួន ២៦ក្បាល ស្តារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងទៅព្រៃធម្មជាតិវិញនូវសត្វព្រៃគ្រប់ប្រភេទចំនួន ៥៩ក្បាល

- គម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការ FFI បានល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន ៥ គឺ អារ៉ែង ឆាយរាប តំបន់ស្តារក្រពើស្ទឹងជាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)

- បានជួសជុលផ្លូវដោយក្រាលក្រួសក្រហមសរុបប្រវែង ២ ០៥០ម៉ែត្រការ៉េ និងកាប់ឆ្ការអនាម័យព្រៃទំហំ ០,២០ហ.ត នៅក្នុងតំបន់សួនសត្វ។

### ៣.៤ ការងារដាំដើមឈើ

- បាននិងកំពុងថែទាំប្រឡាយប្រវែង ១៨ ០០០ម៉ែត្រ ក្នុងនោះប្រឡាយជីកឆ្នាំ២០១៨ ប្រវែង ១០ ០០០ម៉ែត្រ និងឆ្នាំ២០១៩ មានប្រវែង ៨ ០០០ម៉ែត្រ ស្ថិតនៅខេត្តកំពង់ធំ និងខេត្តព្រះសីហនុ

- បានជីកប្រឡាយការពារចម្ការឈើគ្រញូងនៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអន្លង់ថ្ម ខេត្តកំពង់ធំ សម្រេចប្រវែង ២ ០៥០ម៉ែត្រ

- បាននិងកំពុងថែទាំចម្ការឈើទំហំ ៩៣២ហ.ត ក្នុងនោះចម្ការពូជឈើទំហំ ៨៩ហ.ត ឡូត៍បង្ហាញកសិ-រុក្ខកម្មទំហំ ៤៩ហ.ត ចម្ការឈើដាំទំហំ ៧៥៤ហ.ត និងចម្ការរុក្ខទិវា ៩ កក្កដា សរុបទំហំ ៤០ហ.ត ស្ថិតក្នុងខេត្តកំពត កណ្តាល សៀមរាប ព្រះសីហនុ ស្វាយរៀង កំពង់ធំ និងខេត្តក្រចេះ ព្រមទាំងបានធ្វើការភ្ជួរកាត់ សម្អាតស្មៅធ្វើផ្លូវភ្លើងការពារភ្លើងឆេះព្រៃ បាញ់ថ្នាំសម្លាប់ស្មៅ ស្បូវ និងដាំដំឡូងមីចន្លោះរងកុំឲ្យស្មៅដុះ

- បានបណ្តុះកូនឈើគ្រប់ប្រភេទចំនួន ៦៣ ០១៧ដើម ក្នុងនោះថ្នាលបណ្តុះកូនឈើតាមបណ្តាខណ្ឌរដ្ឋបាលព្រៃឈើនៅទូទាំងប្រទេសចំនួន ២៧ ៦៤៧ដើម និងថ្នាលបណ្តុះកូនឈើចំនួន ៦កន្លែង ក្នុងខេត្តចំនួន ៥ រួមមានខេត្តពោធិ៍សាត់ កំពង់ធំ តាកែវ កំពង់ចាម និងខេត្តកណ្តាល២កន្លែងចំនួន ៣៥ ៣៧០ដើម និងបានប្រគេនកូនឈើដល់ព្រះសង្ឃ និងចែកជូនប្រជាពលរដ្ឋចំនួន ២ ៤៦៣ដើម។

### ៣.៥ ការងារនីតិកម្មនិងវិវាទ

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃសរុបចំនួន ១៥៧ករណី ដោយពិន័យអន្តរការណ៍ចំនួន ៦១ករណី និងបញ្ជូនទៅតុលាការចំនួន ៩៦ករណី

- ចំពោះវត្ថុតាងនៃបទល្មើសព្រៃឈើដែលបានចាប់ឃាត់ និងដកហូតរួមមានឈើមូល-ជ្រុងចំនួន ៩ម៣ ឈើអារសរុបចំនួន ៤៤៧ម៣ (ចំនួន ១៣៩ករណី) ផ្ទៃដីព្រៃឈើកាប់រានទំហំ ២៤២ហ.ត នៅខេត្តកំពង់ឆ្នាំង២ករណី ក្រចេះ ៣ករណី ស្ទឹងត្រែង១ករណី សៀមរាប៧ករណី និងខេត្តព្រះវិហារ១ករណី វត្ថុតាងសត្វព្រៃបានចាប់ឃាត់ចំនួន ៤០ក្បាល និង ៤៦,៦០គ.ក្រ និងអនុផល ព្រៃឈើព្រមទាំងឧបករណ៍សម្ភារផ្សេងៗមួយចំនួនទៀត។

### ៣.៦ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- បានបង្កើតរោងអាជីវកម្មអារឈើចំនួន ១កន្លែងរបស់លោក ទូច ថា

- ក្រុមហ៊ុនចំនួន ៤បាននាំចេញផលិតផលរានទេវតា ឈើកែច្នៃ និងជ័រទឹកទៅក្រៅប្រទេសចំនួន ១៩៨ម៣ និងជ័រទឹកចំនួន ២០ តោន

- ក្រុមហ៊ុនចំនួន ១បាននាំចូលឈើកែច្នៃមានចំនួន ១០០ម៣។

### ៣.៧ ការងារចំណូលព្រៃឈើ

- បានចំណូលពីថ្លៃសួយសារផលអនុផលព្រៃឈើចំនួន ២ ៣ ១៤៧ ៥៣០ ៥០៤រៀល។

## ៤ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

**៤.១ ការងារផលិតកម្មសត្វៈ** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តារាជធានី-ខេត្តរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្តៈ

(ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើស្លនដំណាំចំណីសត្វ ការផ្តល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ និងចុះពិនិត្យ និងកែសម្រួលឡជីវឧស្ម័នដែលបានសាងសង់រួចហើយ ដែលមានបញ្ហាបច្ចេកទេសនៅតាមខេត្តគោលដៅ។

### ៤.២ ការងារសុខភាពសត្វ

• លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖ បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យ និងបង្ក្រាបយ៉ាងសកម្មដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ១២ករណី និងរាជធានី-ខេត្តចំនួន ២៤ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ១៤ ៤១៩លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។

• **ការងារផ្សព្វផ្សាយបច្ចេកទេស៖** ប្រជុំពង្រឹងការងារផ្សព្វផ្សាយបច្ចេកទេស និងវគ្គមានមន្ត្រីរាជការ ការគ្រប់គ្រង និងបញ្ចូលព័ត៌មាន App ពិនិត្យលើសេចក្តីសម្រេចបែងចែកភារកិច្ចការិយាល័យ និងប្រជុំពិភាក្សាលើគម្រោងខ្សែចង្វាក់ផលិតកម្មប្រកបដោយភាតរៈបរិស្ថាន CFAVC ជាមួយជំនាញការគម្រោង។

• **ការងារនីតិកម្ម និងវិវាទ**

- បានរៀបចំសេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត និងកំណត់ការគ្រប់គ្រង ចំណីសត្វ វត្ថុធាតុដើម ឬសារធាតុបន្ថែមគ្រប់ប្រភេទដែលធ្វើពាណិជ្ជកម្ម ការផលិត និងការលាយផ្សំ

- បានរៀបចំសេចក្តីប្រកាសស្តីពីនីតិវិធី និងសិទ្ធិពិន័យអន្តរការណ៍លើបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វនៅអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងរៀបចំលិខិតបទដ្ឋានគតិយុត្តមួយចំនួនទៀត។

### ៤.៣ ការងារស្រាវជ្រាវ

• **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១០៦ក្បាល។

• **ការងារស្រាវជ្រាវបសុព្យាបាល៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបចំនួន ១ ០៨៦វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី និងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF)។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ដាយត្រីបានបញ្ចប់ត្រឹមចំនួន ១ ៥០០តោន ស្មើនឹង១២,៥០% នៃផែនការចំនួន ១២ ០០០តោន ប្រៀបធៀបខែឧសភា ឆ្នាំ២០១៩ ថយចុះចំនួន ៨៧០តោន

- នេសាទគ្រួសារក្នុងដែននេសាទអនុវត្តបានចំនួន ២១ ១០០តោន សរុបរយៈពេល៥ខែចំនួន ១១១ ២០០តោន ស្មើនឹង៣២,២៣% នៃផែនការចំនួន ៣៤៥ ០០០តោន ប្រៀបធៀបខែឧសភា ឆ្នាំ២០១៩ ថយចុះចំនួន ៧០០តោន

- នេសាទគ្រួសារតាមវាលស្រែអនុវត្តបានចំនួន ៣ ៨៦០តោន សរុបរយៈពេល៥ខែចំនួន ២៥ ១៧៥តោន ស្មើនឹង ១៧,៣៦% នៃផែនការចំនួន ១៤៥ ០០០តោន ប្រៀបធៀបខែឧសភា ឆ្នាំ២០១៩ ថយចុះចំនួន ១ ៤៥៥តោន។

#### ៥.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ១០ ២០០តោន សរុបរយៈពេល៥ខែចំនួន ៤៥ ៩៦០តោន ស្មើនឹង៤១,៧៨% នៃផែនការចំនួន ១១០ ០០០តោន ប្រៀបធៀបខែឧសភា ឆ្នាំ២០១៩ កើនឡើងចំនួន ២១០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គាអនុវត្តបានចំនួន ២៧ ៣៨៩តោន សរុបរយៈពេល៥ខែចំនួន ១០៤ ៣១១តោន ស្មើនឹង ២៨,៩៨% នៃផែនការចំនួន ៣៦០ ០០០តោន ប្រៀបធៀបខែឧសភា ឆ្នាំ២០១៩ កើនឡើងចំនួន ១៧ ៣៨៥តោន

- ការចិញ្ចឹមក្រពើអនុវត្តបានចំនួន ២១ ៣០០ក្បាល សរុបរយៈពេល៥ខែចំនួន ៦១ ៧០០ក្បាល ស្មើនឹង ២០,៥៧% នៃផែនការចំនួន ៣០០ ០០០ក្បាល ប្រៀបធៀបខែឧសភា ឆ្នាំ២០១៩ កើនឡើងចំនួន ៣០០ក្បាល

- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន ២០ ១០០ ០០០កូន សរុបរយៈពេល៥ខែចំនួន ៧០ ៨០០ ០០០កូន ស្មើនឹង ២៩,៥០% នៃផែនការចំនួន ២៤០ ០០០ ០០០កូន ប្រៀបធៀបខែឧសភា ឆ្នាំ២០១៩ កើនឡើងចំនួនប្រមាណ ៨០០ ០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទអនុវត្តចំនួន ៣ ២៥០តោន សរុបរយៈពេល៥ខែចំនួន ២២ ៤០០តោន ស្មើនឹង២៧,៣២% នៃផែនការចំនួន ៨២ ០០០តោន ប្រៀបធៀបខែឧសភា ឆ្នាំ២០១៩ ថយចុះចំនួន ១ ០៥០តោន

- ផលនេសាទសមុទ្រអនុវត្តបានចំនួន ១ ៣២០តោន សរុបរយៈពេល៥ខែចំនួន ៥ ៤០០តោន ស្មើនឹង៦០% នៃផែនការចំនួន ៩ ០០០តោន ប្រៀបធៀបខែឧសភា ឆ្នាំ២០១៩ កើនឡើងចំនួន ១៥០តោន

- ការផលិតទឹកត្រីអនុវត្តបានចំនួន ៥ ០២០ ០០០លីត្រ សរុបរយៈពេល៥ខែចំនួន ២២ ៣៣០ ០០០លីត្រ ស្មើនឹង៤០,៦០% នៃផែនការចំនួន ៥៥ ០០០ ០០០លីត្រ ប្រៀបធៀបខែឧសភា ឆ្នាំ២០១៩ កើនឡើងចំនួន ២៣០ ០០០លីត្រ។

### ៥.៤ ការត្រួតពិនិត្យនិងបង្រ្កាបបទល្មើសជលផល

- សំណុំរឿងបទល្មើសជលផលមានចំនួន ១៩៣ករណី ប្រៀបធៀបខែឧសភា ឆ្នាំ២០១៩ ថយចុះចំនួន ១១២ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ១៧៦ករណី និងសមុទ្រចំនួន ១៧ករណី។

### ៥.៥ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់ពុំមានការនាំចេញទេក្នុងខែឧសភានេះ សរុបរយៈពេល៥ខែបានចំនួន ១ ១៤០តោន ស្មើនឹង ៧,៦០% នៃផែនការចំនួន ១៥ ០០០តោន ប្រៀបធៀបខែឧសភា ឆ្នាំ២០១៩ ថយចុះចំនួន ២ ៧៥០តោន

- ផលនេសាទកែច្នៃពុំមានការនាំចេញទេក្នុងខែឧសភានេះ សរុបរយៈពេល៥ខែបានចំនួន ២៣២តោន ស្មើនឹង ៤,៦៤% នៃផែនការចំនួន ៥ ០០០តោន ប្រៀបធៀបខែឧសភា ឆ្នាំ២០១៩ ថយចុះចំនួន ១ ៧៤៨តោន។

### ៥.៦ ការប្រមូលចំណូលថវិកា

ចំណូលពីសេវាផ្សេងៗក្នុងផ្នែកជលផលបានចំនួន ១០៣ ២៩៤ ៨០០រៀល សរុបរយៈពេល៥ខែចំនួន ៣៤០ ៥៥២ ៤៨០រៀល ស្មើនឹង១១,៣៧% នៃផែនការចំនួន ២ ៩៩៤ ០០០ ០០០រៀល ប្រៀបធៀបខែឧសភា ឆ្នាំ២០១៩ ថយចុះចំនួន ៣៤ ៨២៦ ៣៩២រៀល។

## ៦ ផ្នែកអគ្គាធិការដ្ឋាន

- បានអញ្ជើញថ្នាក់ដឹកនាំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តប៉ៃលិនធ្វើការណែនាំ និងជំរុញឱ្យអនុវត្តកែលម្អចំណុចខ្វះខាតរបស់មន្ទីរដែលក្រសួងចេញលិខិតឱ្យកែលម្អកន្លងមក

- បានចុះពិនិត្យ និងប្រជុំពិភាក្សាជាមួយឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និងសមត្ថកិច្ចពាក់ព័ន្ធពីបញ្ហាគ្រប់គ្រងវិស័យជលផល និងព្រៃកោងកាងនៅខេត្តកែប

- បានរៀបចំទទួលពាក្យបណ្តឹងតាមរយៈគេហទំព័ររបស់អគ្គាធិការដ្ឋាន

- បានស្រាវជ្រាវព័ត៌មានតាមបណ្តាគេហទំព័រពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ៩៥ករណី

- បានចូលរួមកម្មវិធីប្រជុំ សិក្ខាសាលា និងការងារសង្គមចំនួន ៤លើក។

## ៧ ផ្នែករដ្ឋបាល

- បានទទួលលិខិតសរុបចំនួន ៣៧១ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ១៣៥ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ១៥០ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ៨៦ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល

- បានបញ្ជូនឯកសារនិងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ៨០៤ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ២៥ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ១២ច្បាប់

- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ

- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំដើម្បីក្តាប់ឱ្យបានរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំកិច្ចប្រជុំនិងពិធីបុណ្យផ្សេងៗ ការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ www.maff.gov.kh, Facebook MAFF: ក្រសួង

កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម)។

**៨ ផ្នែកបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស**

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន ៥ ៨៧៥នាក់ (ស្រី១ ៤៣២នាក់) ស្មើនឹង២៤,៣៧% រួមមាន៖

  + អង្គភាពថ្នាក់កណ្តាលចំនួន ២ ៩១៥នាក់ (ស្រី៨២៥នាក់) ស្មើនឹង២៨,៣០%
  + អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ២ ៩៦០នាក់ (ស្រី៦០៧នាក់) ស្មើនឹង២០,៥០%

- បានរៀបចំប្រកាសលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌចំនួន ៤នាក់(ស្រី១នាក់) ក្នុងនោះ សុំលាឈប់ពីការងារចំនួន ២នាក់ និងមរណភាពចំនួន ២នាក់
- បានរៀបចំប្រកាសផ្ទេរមន្ត្រីរាជការផ្ទៃក្នុងក្រសួងចំនួន ៩នាក់
- បានរៀបចំប្រកាសផ្ទេរមន្ត្រីរាជការចូលមកពីក្រៅក្រសួងចំនួន ១នាក់
- បានរៀបចំលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកប្រចាំឆ្នាំចំនួន ១នាក់
- បានរៀបចំប្រកាសដាក់មន្ត្រីរាជការឱ្យចូលបម្រើការងារវិញចំនួន ៣នាក់
- បានរៀបចំប្រកាសដាក់មន្ត្រីរាជការឱ្យចូលបម្រើការងារវិញចំនួន ៤នាក់
- បានរៀបចំប្រកាសដាក់មន្ត្រីរាជការចូលនិវត្តន៍មុនអាយុចំនួន ៤នាក់
- ការងារបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសសរុបចំនួន ៥២នាក់ (ស្រី១២នាក់) ក្នុងនោះ៖
  + ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមសរុបចំនួន ៤៦នាក់ (ស្រី១០នាក់)
  + ការបណ្តុះបណ្តាលក្រៅប្រទេសសរុបចំនួន ៦នាក់។

**៩ ផ្នែកផែនការ និងស្ថិតិ**

- បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់សម្រាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មរាជធានី-ខេត្ត ឆ្នាំ២០១៩-២០២៣ នៅខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ ព្រៃវែង ត្បូងឃ្មុំ កំពង់ចាម កំពង់ធំ ពោធិ៍សាត់ ប៉ៃលិន និងខេត្តបាត់ដំបង
- បានចូលរួមសម្របសម្រួល និងប្រមូលទិន្នន័យលើការសិក្សាខ្សែច្រវាក់តម្លៃផលិតផលកសិកម្ម ដើម្បីជំរុញទីផ្សារប្រកបដោយបរិយាប័ន្នសម្រាប់កសិករខ្នាតតូចនៅខេត្តកណ្តាល កំពង់ចាម ស្វាយរៀង តាកែវ សៀមរាប ព្រះសីហនុ ព្រះវិហារ និងខេត្តកំពង់ស្ពឺ
- បានអនុញ្ញាតជាគោលការណ៍ឲ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ឆ្នាំងបញ្ចេញស្រូវពូជចាស់អន់គុណភាពចំនួន ១០ ៦៣៣គ.ក្រ
- បានចុះប្រមូលព័ត៌មានតម្លៃទីផ្សារកសិផលលក់ដុំក្នុងមួយសប្តាហ៍បីដងគឺថ្ងៃចន្ទ ពុធ និងសុក្រ តម្លៃលក់រាយម្តងក្នុងសប្តាហ៍នូវរៀងរាល់ថ្ងៃព្រហស្បតិ៍តាមបណ្តាទីផ្សារសំខាន់ៗទីតាំងប្រមូលទិញ និងកន្លែងលក់ដុំផលិតផលក្នុងបណ្តារាជធានី-ខេត្តចំនួន២៥
- បន្តការផ្សព្វផ្សាយតម្លៃទីផ្សារកសិកម្មតាមព្រឹត្តិបត្រព័ត៌មានទីផ្សារកសិកម្មតាមប្រព័ន្ធតាម SMS និងតាមគេហទំព័រ www.Agriculturalmarkintinformation.org.kh
- បាននិងកំពុងរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ការគាំពារសង្គម និងបរិស្ថាន" របស់គម្រោងពិពិធកម្មកសិកម្ម។

**១០ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ**

- បានអនុវត្តប្រមូលចំណូលនូវទឹកប្រាក់សរុបចំនួន ៤ ៧០៣ ៤៤០ ៤២៥រៀល
- អង្គភាពប្រមូលចំណូលទាំង៦បានចុះប្រតិបត្តិការចំណូលក្នុងប្រព័ន្ធNRMIS សរុបចំនួន ៤ ៤៨៤ ៤១៥ ០៦៨រៀល
- បានបញ្ចេញអាណត្តិបើកប្រាក់ពីក្រសួងសរុបមានចំនួន ៨៣៩ ៨៥៧ ០០០រៀល
- បានសម្របសម្រួលជាមួយក្រុមការងារក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(FMIS) ចុះមកក្រសួង(នាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ) ចំនួន ២លើក
- បានចូលរួមប្រជុំពិភាក្សាអំពីការកែសម្រួលនីតិវិធីបង់ចំណូលមិនមែនសារពើពន្ធតាមរយៈប្រព័ន្ធទូទាត់អេឡិកត្រូនិច (E-Payment) នៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) ជាមួយក្រុមការងារបច្ចេកទេសនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមប្រព័ន្ធអនឡាញ
- បានចូលរួមចុះពិនិត្យមើលស្ថានភាពសហគមន៍ដាំបន្លែនៅខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ស្ពឺ

- បានចូលរួមប្រជុំពិភាក្សាលើសកម្មភាពការងារប្រមូលចំណូលថ្លៃសម្បទានដីសេដ្ឋកិច្ចបង់ចូលថវិការដ្ឋសម្រាប់ឆ្នាំ២០២០

- បានរៀបចំលិខិតជូនដំណឹងស្តីពីកាតព្វកិច្ចបង់ថ្លៃសម្បទានដីសេដ្ឋកិច្ចជូនក្រុមហ៊ុនចំនួន ១៥ក្រុមហ៊ុន

- បានរៀបចំឯកសារដេញថ្លៃការផ្គត់ផ្គង់ថ្នាំចាក់ការពារ (វ៉ាក់សាំង) និងព្យាបាលសត្វប្រចាំឆមាសទី១ ឆ្នាំ២០២០

- បានបើកសំណើដេញថ្លៃ និងរៀបចំឯកសារកិច្ចសន្យាការផ្គត់ផ្គង់សម្ភារបរិក្ខារពិសោធន៍ និងបសុពេទ្យប្រចាំឆ្នាំ២០២០ និងការងារបោះបង្គោលព្រំប្រទល់ការពារព្រៃលិចទឹក បង្គោលអភិរក្សជលផល បង្គោលព្រំប្រទល់ព្រៃកោងកាង និងរៀបចំស្នាក់ការល្បាតប្រចាំឆ្នាំ២០២០។

## ១១ ផ្នែកសវនកម្មផ្ទៃក្នុង

- បានធ្វើបាយការណ៍វគ្គបណ្តុះបណ្តាលស្តីពីសវនកម្មបច្ចេកវិទ្យាព័ត៌មានសាកល្បង

- បានធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធមុខតំណែងនៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង

- បានចុះធ្វើសវនកម្មតាមផែនការសកម្មភាពសវនកម្មសវនកម្មផ្ទៃក្នុងឆ្នាំ២០២០ បានចំនួន ៤អង្គភាពគឺមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា និងនាយកដ្ឋាននីតិកម្មកសិកម្ម។

## ១២ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- បានចូលរួមក្នុងពិធីចុះហត្ថលេខាលើផែនការ៥ឆ្នាំ រវាងរាជរដ្ឋាភិបាលកម្ពុជា និង IRRI

- ពុំមានការចូលរួមកិច្ចប្រជុំ ទិវា ទស្សនកិច្ច និងសន្និសីទក្រៅប្រទេសរបស់ថ្នាក់ដឹកនាំ

- ពុំមានការចូលរួមសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលក្រៅប្រទេស

- បានសម្របសម្រួលរៀបចំកិច្ចប្រជុំ ទិវា និងវគ្គបណ្តុះបណ្តាលនៅក្នុងប្រទេសចំនួន ២លើក។

## ១៣ ផ្នែកនីតិកម្មកសិកម្ម

### ១៣.១ ការងារអាជីវកម្មជី-ថ្នាំកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២៣ក្រុមហ៊ុន សរុបចំនួន ៣៥៧មុខ

- ផ្តល់លិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២៧ក្រុមហ៊ុន

- ចេញវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៤ក្រុមហ៊ុន

- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៥ក្រុមហ៊ុន

- ចេញលិខិតអនុញ្ញាតលាយផ្សំ ឬវេចខ្ចប់ជាថ្មីជីកសិកម្មចំនួន ២ក្រុមហ៊ុន។

### ១៣.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ៧ក្រុមហ៊ុន សរុបចំនួន ៥៤សំណាក។

### ១៣.៣ ការងារអនុវត្តច្បាប់

- បានធ្វើប្រកាសប្រតិវេទន៍ស្តីពីការនាំចូលថ្នាំកសិកម្ម និងជីកសិកម្មរបស់ក្រុមហ៊ុនពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៨ក្រុមហ៊ុន

- បានធ្វើអធិការកិច្ចត្រួតពិនិត្យបទល្មើសថ្នាំកសិកម្ម និងជីកសិកម្មតាមខេត្តគោលដៅចំនួន ២ខេត្ត ស្មើនឹង២លើក គឺខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបងលើ១០ដេប៉ូ ៤ទីតាំងឃ្លាំងសន្និធិ និង១មធ្យោបាយដឹកជញ្ជូន និងសម្រេចពិន័យអន្តរការណ៍ចំនួន ៣ករណី។

## ១៤ ផ្នែកមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- បានបន្ថែមតំណភ្ជាប់នៅលើគេហទំព័រដើម្បីទាញយកកម្មវិធីទូរស័ព្ទ (Mobile App) របស់ក្រសួងពី Playstore និង AppStore

- បានថែទាំលើគេហទំព័រ (Web) និង Mobile App របស់ក្រសួង និងអង្គភាពក្រោមឱវាទក្រសួងសរុបចំនួន ១៧ (១៦គេហទំព័រ និង១កម្មវិធី) និងគេហទំព័រមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត

- បានតាមដានទិន្នន័យ និងសម្អាត Catch នៅលើ Cloud Server នៃគេហទំព័រទាំង៤១

- បានស្រាវជ្រាវការប្រើប្រាស់រូបភាពផ្កាយរណប Sentinel-2 សម្រាប់វិស័យកសិកម្ម
- បានបង្កើត និងដាក់ឱ្យដំណើរការកម្មវិធីទូរសព្ទដៃឆ្លាតវៃ (Android Mobile App) ដែលមានឈ្មោះថា AgriLibrary របស់បណ្ណាល័យកសិកម្ម
- បានបញ្ចូលឯកសារធ្វើបច្ចុប្បន្នភាពគេហទំព័របណ្ណាល័យ (www.elibrary.maff.gov.kh)។

**១៥ ផ្នែកផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

- បាននិងកំពុងបន្តសហការអនុវត្តគម្រោងកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីធន់នឹងការប្រែប្រួលអាកាសធាតុ (ASPIRE)
- បានប្រជុំកែសម្រួលលើទម្រង់វាយតម្លៃការធានាគុណភាពលើឯកសារផ្សព្វផ្សាយកសិកម្មមានអ្នកចូលរួមចំនួន ១៣នាក់
- បានចុះធ្វើការវិភាគទិន្នន័យទី២ និងវាយតម្លៃជនបទឆាប់រហ័សនៅខេត្តបាត់ដំបងដែលមានកសិករចូលរួមចំនួន ២៥នាក់
- បានចុះទៅថត Video បទយកការណ៍នៅខេត្តកណ្តាល ក្រចេះ និងខេត្តមណ្ឌលគិរីស្តីពីផលិតកម្មរុក្ខជាតិលម្អ ផលិតកម្មដំណាំស្ពៃក្តោប ផលិតកម្មដំណាំការ៉ុត និងបានចាក់ផ្សាយក្នុងកម្មវិធីនាទីកសិកម្មប្រចាំសប្តាហ៍របស់ស្ថានីយទូរទស្សន៍ជាតិ
- កំពុងរៀបចំវេទិកាស្វែងយល់ស្តីពីកសិកម្មលើប្រធានបទការដាក់ចេញផែនការសកម្មភាពឆ្លើយតបទៅនឹងជំងឺកូវីដ-១៩
- បានចុះផលិតនាទីចុះស្រែជាមួយកសិករចំនួន ២ប្រធានបទ គឺ ដំណាំបន្លែ និងការចិញ្ចឹមសត្វនៅខេត្តតាកែវ
- បានបញ្ជូនអត្ថបទបច្ចេកទេសកសិកម្មចំនួន ៦ដើម្បីចាក់ផ្សាយ ក្នុងនោះ បច្ចេកទេសដាំដំណាំប៉េងប៉ោះ ដំណាំខាត់ណាដើម ដំណាំស្ពៃក្តោប ដំណាំស្វាយ ដំណាំពោតធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងបច្ចេកទេសដាំដំណាំម្នាស់ធន់ទៅនឹងការប្រែប្រួលអាកាសធាតុ
- កំពុងរៀបចំ នឹងបោះពុម្ពព្រឹត្តិបត្រព័ត៌មានកសិកម្មចំនួន ២លេខស្តីពីបច្ចេកទេសចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ និងបច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ។

**១៦ ផ្នែកកសិ-ឧស្សាហកម្ម**

- បានចូលរួមប្រជុំផ្សព្វផ្សាយការផ្តល់ឥណទានគាំទ្រដក់សិប្បកម្ម សហគ្រាសធុនតូច និងមធ្យមក្នុងវិស័យកែច្នៃផលិតផលកសិកម្ម វិស័យកសិ-ឧស្សាហកម្ម និងវិស័យកសិកម្មតាមរយៈធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
- បានចុះសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្មរវាងកសិករ និងសហគមន៍អភិវឌ្ឍន៍កសិកម្មកម្ពុជាលើកិច្ចសន្យាដាំដុះចំបក់បារាំង (Macadamia) និងស្លឹកគ្រៃក្រអូប
- បានចុះសិក្សាស្វែងយល់ស្ថានភាពទូទៅខ្សែចង្វាក់តម្លៃស្វាយចន្ទីនៅខេត្តកំពង់ធំ
- ក្រុមការងារបានរៀបចំច្បាប់ផលិតកម្មតាមកិច្ចសន្យាចំនួន ៤ដង
- បាននិងកំពុងវិភាគ MGO លើពោត សណ្តែកធ្វើចរាចរចែកចាយលើទីផ្សារ
- បានរៀបចំកិច្ចប្រជុំជាមួយរោងចក្រសិប្បកម្មកែច្នៃពាក់ព័ន្ធ និងការទទួលឥណទានធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម។

**១៧ ការស្រាវជ្រាវ ការអប់រំ និងការបណ្តុះបណ្តាលកសិកម្ម**

**១៧.១ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា**

- បានចុះជ្រើសរើសទីតាំងពិភាក្សាការងារពិសោធន៍ស្រាវជ្រាវ និងប្រមូលសំណាកសមាសភាពចង្រៃលើដំណាំស្រូវនៅខេត្តព្រៃវែង និងខេត្តតាកែវ
- បានចុះត្រួតពិនិត្យការងារពិសោធន៍នៅខេត្តបាត់ដំបង
- បានចុះដាំពិសោធន៍ស្រូវបង្កើនរដូវ និងជ្រើសរើសទីតាំងពិសោធន៍សម្រាប់រដូវវស្សាឆ្នាំ២០២០ នៅខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង
- បានចុះចែកគ្រាប់ពូជស្រូវចំនួន ៤២៥គ.ក្រជូនកសិករចំនួន ៧៥គ្រួសារនៅខេត្តឧត្តរមានជ័យ
- បានចុះចែកពូជស្រូវចំនួន ៤៥០គ.ក្រជូនកសិករចំនួន ៨០គ្រួសារ និងត្រួតពិនិត្យការងារពិសោធន៍នៅខេត្តត្បូងឃ្មុំ និងខេត្តព្រះវិហារ
- បានចុះជ្រើសរើសទីតាំងពិសោធន៍ និងប្រមូលសំណាកដី នៅខេត្តកំពង់ស្ពឺ
- បានបន្តបញ្ចូលទិន្នន័យវិភាគលទ្ធផលពិសោធន៍ជាបណ្តើរៗនិងបន្តចងក្រងកាតាឡុកពូជម្ទេសនិងក្រសក់ស្រូវ។

**១៧.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

- បានស្រង់ទិន្នន័យជ័រកៅស៊ូឡូតិ៍ពិសោធន៍ក្លូន IRAA01 IRAA10 និង SSCT01

- បានថែទាំកូនកៅស៊ូស៊ីដលិង ច្បារបង្កាតពូជ និង GSET02
- បានសិក្សាមាឌឈើកៅស៊ូតាមក្លូននីមួយៗក្នុងឡូត៍ពិសោធន៍ក្លូន IRAA04
- បានស្រង់ទិន្នន័យទឹកជ័រលើចម្ការពិសោធន៍សក្តានុពលទិន្នផលលើប្រព័ន្ធចង្វាក់ចៀរជ័រ (d4) ចំនួន ៩ចម្ការពិសោធន៍ និងចម្ការពិសោធន៍ប្រព័ន្ធចៀរជ័រចង្វាក់រង្វើល (d3 d4 d5 d6) ចំនួន ២ចម្ការពិសោធន៍
- បានរៀបចំផែនការស្រាវជ្រាវលើបច្ចេកទេសថ្មីៗនៃការប្រមូលផលទឹកជ័រដើម្បីធ្វើសហប្រតិបត្តិការរួមគ្នាជាមួយបណ្ឌិតសភាវិទ្យាសាស្ត្រកសិកម្មត្រូពិកចិន (CATAS)
- បានថែទាំឡូត៍កៅស៊ូចៀរជ័រដូចជាលាបថ្នាំរំញោច និងលាបខ្លាញ់គោលើដើមកៅស៊ូចៀរជ័រ
- បានធ្វើតេស្តរកសំណើមលើជ័របង្កកដែលប្រើអាស៊ីតទាំង៣ប្រភេទ។

## ១៧.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតកំពុងសិក្សាក្នុងឆ្នាំសិក្សា២០១៩-២០២០ សរុបចំនួន ៣ ២៥៦នាក់ ចែកចេញជា១០ មហាវិទ្យាល័យ គឺៈ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រជលផល កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមហាវិទ្យាល័យវិទ្យាសាស្ត្រកៅស៊ូ និងសាលាក្រោយឧត្តម
- បានរៀបចំវគ្គបណ្តុះបណ្តាលជូនសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូស្តីពីការគ្រប់គ្រង និងផ្តល់សេវាអប់រំតាមប្រព័ន្ធអេឡិចត្រូនិកដោយសហការជាមួយក្រុមហ៊ុន Poscar Digital
- បាននិងកំពុងរៀបចំមេរៀន និងវិធីសាស្ត្របង្រៀននិស្សិតតាមប្រព័ន្ធអេឡិចត្រូនិក និង Online
- បានរៀបចំផែនការសកម្មភាពជាមួយគម្រោង FoodSTEM Erasmus+ ក្នុងការបង្កើតសាលស្ទូឌីយ៉ូសម្រាប់បម្រើការសិក្សាពីចម្ងាយ និងបន្ទប់សិក្សាទំនើបតាមប្រព័ន្ធ Online
- បានបង្កើតស្នាដៃថ្មីផលិតឧបករណ៍រែងដីកំប៉ុសជន្លេនសម្រាប់ជូនកសិករនៅខេត្តកំពង់ឆ្នាំង រៀបចំពិសោធន៍សាកល្បងសមត្ថភាពម៉ាស៊ីនបូមទឹកប្រើប្រាស់ប្រេងឥន្ធនៈជីវឧស្ម័ន និងទទួលបានឧបករណ៍វាស់លំហូរបរិមាណហ្គាសពីអង្គការ UNIDO សម្រាប់ប្រើក្នុងការធ្វើ Feasibility Study ឡជីវឧស្ម័នខ្នាតធំនៅកសិដ្ឋានចិញ្ចឹមខ្លាធំ បូមធ្យម និងតាមរោងចក្រកែច្នៃម្សៅមី
- បានបើកវគ្គបណ្តុះបណ្តាលជូនលោកគ្រូ អ្នកគ្រូស្តីពីការប្រើប្រាស់ម៉ាស៊ីន x-ray និងបានអនុវត្តសាកល្បងព្យាបាលសត្វកើតជំងឺ pavo ដោយជោគជ័យ
- បាននិងកំពុងធ្វើការពិសោធន៍ស្រាវជ្រាវលើម្ហូបអាហារ ដូចជា ការកែច្នៃនំម៉ាហ្វីនពីម្សៅដំឡូងឈាមមាន់ ការស្វែងរកមីក្រូសរីរាង្គនៅក្នុងផលិតផលជ្រក់ផ្សេងៗ និងផលិតម្សៅផុងត្រាវលាយខ្ទិះ។

## ១៧.៤ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០១៩-២០២០ សរុបចំនួន ១ ០៨៨នាក់ (ស្រី៤៥៤នាក់) លើជំនាញៈ កសិកម្ម ជលផល ព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ សាកវប្បកម្ម ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិ-ឧស្សាហកម្ម និងសុរិយោដី
- បន្តការរៀបចំកែលម្អកម្មវិធីសិក្សា
- បានចុះសិក្សាពីលទ្ធភាពបូមទឹកដោយប្រើចរន្តទឹកហូរពីធម្មជាតិ
- បានចុះសិក្សាទីតាំងដីសម្រាប់ធ្វើការសិក្សាស្រាវជ្រាវពិសោធន៍នៅខេត្តក្រចេះ
- បន្តការស្រាវជ្រាវលើ ផ្កាអ័រគីដេ ចេក ស្វាយចន្ទី ត្រីជាដើម
- បាននិងកំពុងដំណើរការសាងសង់អគារសម្រាប់ចិញ្ចឹមត្រីឆ្លូក ត្រីដំរី និងមាន់
- បាននិងកំពុងដំណើរការសាងសង់កសិដ្ឋានចិញ្ចឹមគោយកទឹកដោះ។

## ១៧.៥ វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០១៩-២០២០ សរុបចំនួន ៧១៩នាក់ (ស្រី២៨៤នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម ក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ
- បានរៀបចំពិសោធន៍ជីសរីរាង្គលើការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់
- បានរៀបចំសាកល្បងផលិតមេជី Lacto Bacellus និងពិសោធន៍ឥទ្ធិពលមេជីលើការលូតលាស់ដំណាំស្ពៃក្តោប និងស្រូវនៅខេត្តកំពង់ចាម
- បានរៀបចំពិសោធន៍ដំណាំលើទឹកដោយប្រើប្រាស់ទឹកការលើអាងចិញ្ចឹមត្រីក្នុងកន្លែងពិសោធន៍ផលផលរបស់វិទ្យាស្ថាន

- បានពិសោធន៍ប្រៀបធៀបការបំផ្លាញរបស់កន្លាតចង្រៃលើដំណាំខាត់ណាផ្កា
- បានធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហម
- បានបន្តការងារមន្ទីរពិសោធន៍ចិញ្ចឹម និងភ្ញាស់ជង្រុកនាងព្រៃ
- បានសហការជាមួយលោកសាស្ត្រាចារ្យមកពីសាកលវិទ្យាល័យជាតិកាង វ៉ុន ចុះធ្វើការស្រាវជ្រាវប្រភេទរុក្ខជាតិនៅកម្ពុជា និងចម្រាញ់ប្រេងរុក្ខជាតិចេញពីម្រេចបង្កើតបានជាទឹកអប់
- បានចូលរួមបណ្តុះបណ្តាលកសិករជាមួយដៃគូរបស់ក្រុមហ៊ុន និងធ្វើការស្រាវជ្រាវរួមគ្នាអំពីការកែច្នៃកសិផលលើដំណាំស្វាយចន្ទី ប៉េងប៉ោះ ល្ពៅ ល្ពៅ ក្រូចថ្លុង ស្លឹកគ្រៃ និងម្រេច។

## III-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាធ្វើការដាំដុះបានចំនួន ៦៣៩ ១៥៨ហ.ត ស្មើនឹង២៤,៧០% នៃផែនការចំនួន ២ ៥៨៨ ១៣០ហ.ត និងស្ថានភាពទឹកភ្លៀងធ្លាក់នៅក្នុងតំបន់ពីកម្រិតខ្សោយទៅបង្គួរនៅតាមរាជធានី-ខេត្ត។ ក្រសួងក៏បានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើយន្តការ និងបទដ្ឋានបច្ចេកទេសគន្លឹះសំខាន់ៗតាមការចាំបាច់ និងសហ-ការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការតាមដានវាយតម្លៃអំពីការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ដូចជាការជំរុញឱ្យចុះត្រួតពិនិត្យ និងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វឈឺក្នុងតំបន់ផ្ទុះជំងឺ បទល្មើសព្រៃឈើ និងជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រង ការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងក៏បានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រ គោលនយោបាយតាមអនុវិស័យសំខាន់ៗឱ្យសម្រេចបាននូវលទ្ធផលល្អប្រសើរតាមផ្នែកនីមួយៗស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម។

ជារួម ដោយមានការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា គួបផ្សំនឹងការខិតខំឧស្សាហ៍ព្យាយាម និងការផ្លាស់ប្តូរទម្លាប់របស់ប្រជាកសិករផង បានជំរុញឱ្យដំណើរការផលិតកម្មកសិកម្មទទួលបានជោគជ័យ និងជម្នះដោះស្រាយនូវរាល់ការលំបាកផ្សេងៗប្រកបដោយមោទនភាព ពិតមែនតែនៅមានបញ្ហាប្រឈមខ្លះៗក៏ដោយ។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ

- បន្តវិធានការជំរុញការងារបង្កបង្កើនផលកសិកម្មនៅក្នុងរដូវវស្សាឆ្នាំ២០២០ ដែលនឹងឈានចូលមកដល់នាពេលដ៏ខ្លីខាងមុខនេះ
- បន្តធ្វើការពិនិត្យសន្និធិស្បៀងសម្រាប់ឆ្លើយតបទៅនឹងហានិភ័យនៃការឆ្លងរាលដាលជំងឺកូវីដ-១៩
- បន្តវិធានការបន្ទាន់ដើម្បីដោះស្រាយបញ្ហានៃការធ្លាក់ចុះថ្លៃផលិតផលផ្លែស្វាយ
- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណ និងគុណភាពតាមផែនការកំណត់ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង
- បន្តជំរុញ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាន និងស្ថានីយ

- ត្រៀមលក្ខណៈមានដូចជាៈ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់នឹងជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្មសម្រាប់ការងារបង្កបង្កើនផល

- បន្តអង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍កូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ។

## ២ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗទៀត ព្រមទាំងចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទរួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង

- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- ចុះពិនិត្យអនាម័យសត្តឃាតដ្ឋាន ផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកគ្រុនចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត

- បន្តការតាមដានស្ថានភាពជំងឺស៊ូណូសជាប្រចាំនៅតាមបណ្តារាជធានី-ខេត្ត

- ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យ កន្លែងផ្ទុះជំងឺ និងកន្លែងដែលរាលដាលជំងឺផ្តាសាយបក្សី (H5N1) និងជំងឺ A(H1N1)

- បន្តអនុវត្តការបង្កាត់ពូជជ្រូកដោយសិប្បនិម្មិត។

## ៣ ផ្នែករុក្ខាព្រៃឈើ

- ខិតខំបន្តត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើឲ្យបានហ្មត់ចត់ ព្រមទាំងចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតដើម្បីលុបបំបាត់សកម្មភាពដឹកជញ្ជូនឈើខុសច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់

- បន្តផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទប្បញ្ញត្តិ បទបញ្ជា លិខិតបទដ្ឋានគតិយុត្ត ជាពិសេសសេចក្តីជូនដំណឹងលេខ១៣៤៨ សជណ.កច ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីឲ្យបានជ្រួតជ្រាបដល់មូលដ្ឋានភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង រាជធានី-ខេត្តទូទាំងប្រទេស ព្រមទាំងមានចំណាត់ការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ និងឲ្យមានប្រសិទ្ធភាពខ្ពស់ពាក់ព័ន្ធនឹងការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីរំភាតយកដីធ្វើកម្មសិទ្ធិ

- បន្តជំរុញការដាំដុះស្តារព្រៃឈើឡើងវិញដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ

- បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងទំនាក់ទំនងទ្វេភាគី និងពហុភាគីសម្រាប់ការបណ្តុះ-បណ្តាលសមត្ថភាពដល់មន្ត្រីរដ្ឋបាលព្រៃឈើ និងភាគីពាក់ព័ន្ធក្នុងការចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើសត្វព្រៃ។

## ៤ ផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលឱ្យបានតឹងរ៉ឹងបំផុត

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"។

## ៥ ផ្នែកពាក់ព័ន្ធផ្សេងៗ

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាម

រាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់ជី-ថ្នាំកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់ជី-ថ្នាំកសិកម្ម ដើម្បីសុខភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា អភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាឱ្យមានផលិតភាពខ្ពស់ដោយគិតគូរទៅលើការប្រែប្រួលអាកាសធាតុ និងស្តង់ដារ។

ថ្ងៃអង្គារ ១២កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**